**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីអំពីពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០១៨
## ថ្ងៃទី២៧ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨
## នៅអគារពាណិជ្ជកម្ម និងពិព័រណ៍កោះពេជ្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់ ក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារធ្វើ សិស្ស និស្សិត និងសាធារណជនមេត្តាជ្រាបថា តាមរយៈកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា រាជធានីភ្នំពេញ (ស.ស.យ.ក) និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ក្រសួងនឹងរៀបចំពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០១៨ (National Career and Productivity Fair 2018) ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨ ពីម៉ោង ០៨:០០ នាទីព្រឹក ដល់ម៉ោង ២០:០០ នាទីយប់ នៅអគារពាណិជ្ជកម្ម និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ។ ព្រឹត្តិការណ៍ការងារដ៏ធំជាងគេបំផុតនៅកម្ពុជាលើកទី៨នេះ រៀបចំឡើងក្នុងគោលបំណងដើម្បី៖

- បង្កើតជាវេទិកាជួបជុំគ្នានៅមួយកន្លែងដោយងាយស្រួល សម្រាប់និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងអ្នកស្វែងរកការងារធ្វើ ធ្វើការផ្លាស់ប្តូរ និងចែករំលែកព័ត៌មានទីផ្សារការងារ ព្រមទាំងលើកកម្ពស់ការយល់ដឹង និងបណ្តុះគំនិតអំពីផលិតភាពការងារ។
- និយោជកអាចធ្វើការផ្សព្វផ្សាយពីតម្រូវការជ្រើសរើសកម្លាំងពលកម្ម នាពេលបច្ចុប្បន្ន និងអនាគត ដើម្បីទាក់ទាញអ្នកស្វែងរកការងារធ្វើដែលមានសមត្ថភាព។
- អ្នកស្វែងរកការងារធ្វើអាចដាក់ពាក្យរកការងារនៅនឹងកន្លែងផ្ទាល់ ព្រមទាំងទទួលបានព័ត៌មានអំពីឱកាសការងារនាពេលបច្ចុប្បន្ន និងអនាគត ព្រមទាំងឱកាសក្នុងការអភិវឌ្ឍជំនាញនានា។
- អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលអាចផ្សព្វផ្សាយកម្មវិធីសិក្សា វគ្គសិក្សា និងកម្មវិធីអភិវឌ្ឍជំនាញគ្រប់ប្រភេទ។
- បង្ហាញអំពីគំនិត ជំនាញ និងបច្ចេកវិទ្យា សម្រាប់លើកកម្ពស់ផលិតភាព ប្រសិទ្ធភាពក្នុងអាជីវកម្ម តាមរយៈការបង្ហាញជោគជ័យគំរូរបស់កម្មករនិយោជិតឆ្នើម និងការចែករំលែកបទពិសោធន៍ ចំណេះដឹង ចំណេះធ្វើរបស់អ្នកជំនាញល្បីៗជាតិ និងអន្តរជាតិ។
- ផ្តល់វេទិកាសម្រាប់បង្កើតបណ្តាញទំនាក់ទំនងផ្នែកធនធានមនុស្ស។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង ស្ថាប័ន ក្រុមហ៊ុន សហគ្រាស អង្គការជាតិ/អន្តរជាតិ អ្នកស្វែងរកការងារធ្វើ និងសាធារណជន ដែលមានបំណងចូលរួមតាំងបង្ហាញ និងចូលរួម ឬត្រូវការព័ត៌មានពិស្តារអំពីកម្មវិធីពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០១៨ សូមទំនាក់ទំនងមកទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈទូរសព្ទលេខ ០១៧ ៨៧១ ៨០៧ ឬចូលមើលគេហទំព័រ www.event.nea.gov.kh ។

ថ្ងៃ ពុធ ១១កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ សីហា ឆ្នាំ២០១៨

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩